# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

# អនុស្សរណៈយោគយល់

## រវាង

## គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

## និង

## អង្គការ A21 Foundation

## ស្តីពី

## កិច្ចសហប្រតិបត្តិការលើការបង្ការ ទប់ស្កាត់ ការពារ និងកំណត់អត្តសញ្ញាណបឋមជនរងគ្រោះដោយអំពើជួញដូរមនុស្ស

# បុព្វកថា

**ដោយហេតុថា៖** គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) បានសម្តែងនូវបំណងប្រាថ្នា ក្នុងការរួមសហការជាមួយអង្គការ A21 Foundation ដែលមានបេសកកម្ម ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងរាល់ទម្រង់ នៃការកេងប្រវ័ញ្ចគ្រប់រូបភាពលើកុមារ ព្រមទាំងកិច្ចការពារជនរងគ្រោះ ជាពិសេសកុមារដែលមានសភាពមិនប្រក្រតី ។

**ដោយយល់ថា៖** ដើម្បីអនុវត្តកម្មវិធីបង្ការ ទប់ស្កាត់ កិច្ចការពារជនរងគ្រោះ និងការកំណត់អត្តសញ្ញាណបឋមរបស់ជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស ប្រកបដោយប្រសិទ្ធភាពខ្ពស់ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) និង អង្គការ A21 Foundation តាមរយៈយន្តការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ បានព្រមព្រៀងលើកិច្ចសហប្រតិបត្តិការ ដូចខាងក្រោម៖

## ប្រការ១
## គោលបំណង

អនុស្សរណៈយោគយល់នេះ មានគោលបំណងកំណត់អំពីកិច្ចសហប្រតិបត្តិការ រវាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) និងអង្គការ A21 Foundation ដើម្បីបង្ការ ទប់ស្កាត់ ការពារ និងកំណត់អត្តសញ្ញាណបឋមជនរងគ្រោះដោយអំពើជួញដូរមនុស្ស ។

ការពិពណ៌នាសង្ខេបពីគម្រោង នៃកិច្ចសហប្រតិបត្តិការ មានកំណត់ក្នុងឧបសម្ព័ន្ធនៃអនុស្សរណៈយោគយល់នេះ ។

## ប្រការ ២
## ការទទួលខុសត្រូវរបស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)

ដើម្បីឱ្យការអនុវត្តអនុស្សរណៈយោគយល់នេះប្រកបដោយគុណវុឌ្ឍិ និងប្រសិទ្ធផល គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) បានព្រមព្រៀងដូចខាងក្រោម៖

១- អនុញ្ញាតឱ្យអង្គការ A21 Foundation បំពេញការងាររបស់ខ្លួន ដោយអនុវត្តស្របទៅតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតនៃព្រះរាជាណាចក្រកម្ពុជា។

២- សម្របសម្រួលឱ្យគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ថ្នាក់ក្រោមជាតិ **(គ.ខ.ប.ជ)** ក្នុងខេត្តគោលដៅ ចូលរួមសហការជាមួយអង្គការ A21 Foundation ក្នុងការអប់រំផ្សព្វផ្សាយ លើកកម្ពស់ការយល់ដឹងអំពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព ការការពារ ការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស និងរាល់ទម្រង់នៃការកេងប្រវ័ញ្ចផ្សេងទៀត។

៣- សម្របសម្រួលឱ្យ **គ.ខ.ប.ជ** ក្នុងខេត្តគោលដៅ សហការជាមួយអង្គការ A21 Foundation ដើម្បីកំណត់អត្តសញ្ញាណបឋមរបស់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចផ្សេងៗ តាមរយៈការសម្ភាសដែលមានលក្ខណៈបច្ចេកទេសត្រឹមត្រូវ ដោយមានការចូលរួមពីផ្នែកពាក់ព័ន្ធនៃអង្គភាពជំនាញចម្រុះ (MultidisciplinaryTeam) ក្រុមការងារនៃលេខាធិការដ្ឋានក្នុងខេត្តគោលដៅ និងផ្នែកជំនាញពាក់ព័ន្ធ ធ្វើការសម្ភាសប្រកបដោយសីលធម៌វិជ្ជាជីវៈចំពោះជនរងគ្រោះ និងសាក្សីជាកុមារ ដោយផ្អែកលើឧត្តមប្រយោជន៍ និងសុខុមាលភាពរបស់កុមារជាចម្បង ។

៤- សម្របសម្រួលឱ្យគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សក្នុងខេត្តគោលដៅជំរុញលើកទឹកចិត្តអង្គភាពជំនាញពាក់ព័ន្ធ បានសហការជាមួយអង្គការ A21 Foundation ដើម្បីចូលរួមកិច្ចប្រជុំពិគ្រោះយោបល់អំពីការគ្រប់គ្រង ការថែទាំបណ្តោះអាសន្ន ចំពោះកុមារដែលជាជនរងគ្រោះ និងអាចធានាថាសក្ខីកម្មរបស់កុមារ នឹងត្រូវបានមន្ត្រីនគរបាលយុត្តិធម៌ទទួលយកទៅប្រើប្រាស់ ដើម្បីបំពេញបន្ថែមលើការស៊ើបអង្កេត និងការប្រមូលភស្តុតាងមុនពេលសំណុំរឿងត្រូវបានបញ្ជូនទៅតុលាការ ។

៥- អនុញ្ញាតឱ្យអង្គការ A21 Foundation ចូលរួមក្នុងកិច្ចប្រជុំដែលរៀបចំឡើងដោយគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) ដើម្បីចែករំលែកព័ត៌មាន បទពិសោធន៍ និងសមិទ្ធផលការងារ ដែលទទួលបានទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ពាក់ព័ន្ធនឹងការបង្ការទប់ស្កាត់ ការកំណត់អត្តសញ្ញាណបឋមជនរងគ្រោះដោយអំពើជួញដូរមនុស្ស ព្រមទាំងការផ្តល់នូវសេវាសមស្របនានាដើម្បីបង្កើនប្រសិទ្ធភាពការងារ ។

## ប្រការ ៣

## ការទទួលខុសត្រូវរបស់អង្គការ A21 Foundation

ផ្អែកតាមតួនាទីដែលទទួលបានការឯកភាពពីគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) អង្គការ A21 Foundation បានព្រមព្រៀងដូចខាងក្រោម៖

១- ធ្វើការងារបង្ការ និងទប់ស្កាត់អំពើជួញដូរមនុស្ស ដោយសហការជាមួយអាជ្ញាធរ និងសមត្ថកិច្ចពាក់ព័ន្ធ ធ្វើការអប់រំផ្សព្វផ្សាយ តាមសហគមន៍ងាយរងគ្រោះ និងសាលាបឋមសិក្សា អំពីវិធានការទប់ស្កាត់អំពើជួញដូរមនុស្ស និងទម្រង់នៃការកេងប្រវ័ញ្ចគ្រប់រូបភាពលើកុមារ ការធ្វើចំណាកស្រុកដោយគ្មានសុវត្ថិភាព ព្រមទាំងអំពីគុណតម្លៃ និងសិទ្ធិមូលដ្ឋានរបស់កុមារ។

២- ធ្វើការកំណត់អត្តសញ្ញាណជនរងគ្រោះជាពិសេសកុមារ តាមបែបកោសលវិច័យ និងវិធីសាស្ត្រកុមារមេត្រី ដោយប្រើប្រាស់មជ្ឈមណ្ឌលតស៊ូមតិសម្រាប់កុមារ របស់អង្គការ A21 Foundation ដោយគោរពតាមនីតិវិធីដែលមានចែងក្នុង **"គោលការណ៍ណែនាំ ស្តីពីបែបបទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប"** របស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីជាប្រយោជន៍ដល់កុមាររងគ្រោះ និងកុមារដែលធ្វើជាសាក្សីនៅក្នុងនីតិវិធីរឿងក្តីដែលពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស ។

៣- រាល់ការសម្ភាសដើម្បីកំណត់អត្តសញ្ញាណបឋមរបស់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស អង្គការ A21 Foundation ត្រូវសហការឱ្យបានជិតស្និទ្ធជាមួយអង្គភាពជំនាញតាមវិស័យ មានដូចជា៖ ផ្នែកសុខភាពផ្លូវកាយនិងផ្លូវចិត្ត ផ្នែកច្បាប់ មន្ត្រីអនុវត្តន៍ច្បាប់ ផ្នែកការពារកុមារ ផ្នែកតស៊ូមតិដើម្បីជនរងគ្រោះ និងផ្នែកវិជ្ជាជីវៈពាក់ព័ន្ធផ្សេងទៀត ដើម្បីពិនិត្យទៅលើករណីនីមួយៗ និងធ្វើការសម្រេចចិត្តឆ្លើយតបជារួមដោយផ្អែកលើឧត្តមប្រយោជន៍ និងសុខុមាលភាពរបស់កុមារជាចម្បង ជាពិសេសកុមារដែលមានសភាពមិនប្រក្រតី និងផ្តល់នូវសេវាសុខភាពផ្លូវកាយនិងផ្លូវចិត្ត ការគាំទ្រការសិក្សាអប់រំ ការប្រឹក្សាយោបល់ ការបណ្តុះបណ្តាលវិជ្ជាជីវៈ ការជួយគាំទ្រក្នុងការបង្កើត អាជីវកម្មខ្នាតតូចសម្រាប់គ្រួសារ ដើម្បីបំពេញតម្រូវការរបស់កុមាររងគ្រោះដែលត្រូវបានគេជួញដូរ ឬកេងប្រវ័ញ្ចគ្រប់រូបភាព ។

៤- កុមារដែលសង្ស័យថាត្រូវបានរំលោភបំពាន ឬជួញដូរ ឬកេងប្រវ័ញ្ច នឹងត្រូវបានសហការពីអាជ្ញាធរពាក់ព័ន្ធ ស្របតាមនីតិវិធីដើម្បីបញ្ជូនទៅកាន់មជ្ឈមណ្ឌលតស៊ូមតិសម្រាប់កុមារ ដែលជាកន្លែងសុវត្ថិភាពដោយមានការចូលរួមពីអ្នកមើលថែទាំ ឬអាណាព្យាបាល ឬមនុស្សពេញវ័យផ្សេងទៀតដែលកុមារអាចទុកចិត្តបាន។

៥- សហការជាមួយអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ក្នុងការធ្វើមាតុភូមិនិវត្តន៍ជនរងគ្រោះ និងផ្តល់សេវាថែទាំបន្ត បន្ទាប់ពីនីតិវិធីនៃការកំណត់អត្តសញ្ញាណបឋមត្រូវបានបញ្ចប់ និងធ្វើការបញ្ជូនជនរងគ្រោះទៅកន្លែងដែលមានសុវត្ថិភាព និងមានស្ថិរភាពដើម្បីទទួលបានសេវាសមស្រប។

៦- ក្នុងតួនាទីជាអ្នកធ្វើការងារវិស័យសង្គមកិច្ច ត្រូវចូលរួមសហការជាមួយមន្ត្រីអនុវត្តន៍ច្បាប់តាមការចាំបាច់ ដើម្បីគាំទ្រដល់ការជួយសង្គ្រោះជនរងគ្រោះចេញពីកន្លែងដែលត្រូវបានគេកេងប្រវ័ញ្ច ដោយផ្តល់សេវាជំនួយផ្នែកច្បាប់ និង/ឬជួយស្វែងរកសេវាគាំទ្រចាំបាច់នានាផងដែរ។

៧- អង្គការ A21 Foundation នឹងត្រូវប្រើប្រាស់ថវិកាជំនួយដើម្បីបម្រើដល់ការអនុវត្តសកម្មភាពរបស់គម្រោងឱ្យមានប្រសិទ្ធភាពចំគោលដៅ ដោយគោរពឱ្យបានខ្ជាប់ខ្ជួននូវច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត នៃព្រះរាជាណាចក្រកម្ពុជា ។

៨- អង្គការ A21 Foundation មិនត្រូវអនុញ្ញាតឱ្យភ្នាក់ងាររបស់ខ្លួន ចូលរួមធ្វើរាល់សកម្មភាពទាំងឡាយណាផ្ទុយពីច្បាប់ ដែលអាចប៉ះពាល់ដល់សុវត្ថិភាព ស្ថិរភាព សន្តិសុខ និងសណ្តាប់ធ្នាប់សង្គម ឬសកម្មភាពដទៃទៀតដែលអាចបង្កអន្តរាយដល់ការឯកភាពជាតិ វប្បធម៌ និងប្រពៃណីជាតិរបស់ពលរដ្ឋកម្ពុជា។

៩- ប្រតិបត្តិរាល់សកម្មភាព និងអនុវត្តកម្មវិធីគម្រោងមនុស្សធម៌នៅក្នុងព្រះរាជាណាចក្រកម្ពុជាក្នុងក្របខណ្ឌនៃមូលនិធិ និងធនធានបុគ្គលិករបស់ខ្លួន ព្រមទាំងធានាឱ្យបានថា រាល់ភស្តុតាង នៃការប្រព្រឹត្តល្មើសនឹងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ដែលខ្លួនប្រមូលបាន នឹងត្រូវបញ្ជូនទៅនគរបាលដែលមានសមត្ថកិច្ចជំនាញសម្រាប់ចាត់វិធានការបន្ត ។

១០- ចូលរួមតែក្នុងសកម្មភាពមនុស្សធម៌ដែលទទួលបានការអនុញ្ញាតពីរាជរដ្ឋាភិបាលកម្ពុជាដើម្បីសុខុមាលភាពសង្គម ប្រយោជន៍សាធារណៈ ជៀសវាងដាច់ខាតការចូលរួមពាក់ព័ន្ធគ្រប់សកម្មភាពនយោបាយ ។

១១- ធ្វើប្រតិបត្តិការ និងគ្រប់គ្រងគម្រោងដោយអនុលោមទៅតាមអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ ដែលព្រះរាជាណាចក្រកម្ពុជាបានផ្តល់សច្ចាប័ន ។

១២- គាំទ្រដល់ការបណ្តុះបណ្តាលពង្រឹងសមត្ថភាពមន្ត្រីអនុវត្តន៍ច្បាប់ និងអ្នកពាក់ព័ន្ធក្នុងកិច្ចប្រតិបត្តិការបង្ក្រាប សង្គ្រោះ និងផ្តល់សេវាដល់ជនរងគ្រោះ។

១៣- កម្មវិធី Night Outreach ៖ ធ្វើការអប់រំដល់កុមារនៅតាមចិញ្ចើមផ្លូវក្នុងក្រុងប៉ោយប៉ែត និង ក្រុងសៀមរាបនៅពេលយប់ អំពីការការពារខ្លួនពីការជួញដូរ ការកេងប្រវ័ញ្ច និងការរំលោភបំពាននានា ព្រមទាំងផ្តល់អាហារ ដោយសហការជាមួយអាជ្ញាធរមូលដ្ឋានក្នុងការកំណត់អត្តសញ្ញាណបឋមរបស់កុមារដែលរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចគ្រប់រូបភាព ដើម្បីរៀបចំផែនការសកម្មភាពឆ្លើយតបឱ្យចំគោលដៅទៅតាមករណីនីមួយៗ ។

១៤- ធ្វើការសហការជាមួយក្រុមជំនួយកិច្ចការការងារបង្ការទប់ស្កាត់ នៃអគ្គលេខាធិការដ្ឋាន គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) ដើម្បីរៀបចំកម្មវិធីសិក្សា និងតាមដានវាយតម្លៃគុណភាពនៃការអនុវត្តនៅតាមសាលាបឋមសិក្សា មធ្យមសិក្សា និងសកលវិទ្យាល័យ ដោយផ្តោតលើប្រធានបទស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ទម្រង់នៃការកេងប្រវ័ញ្ចផ្សេងៗ វិធីការពារខ្លួន សិទ្ធិកុមារ សិទ្ធិមនុស្ស និងការអភិវឌ្ឍសហគមន៍ ដល់សិស្ស និងនិស្សិត ។

១៥- សហការជាមួយក្រុមការងារជំនាញ ធ្វើការបណ្តុះបណ្តាលដល់មន្ត្រីអនុវត្តន៍ច្បាប់ មន្ត្រីជួរមុខ បុគ្គលិកមន្ទីរពេទ្យ អាជ្ញាធរមូលដ្ឋាន អំពីការកំណត់អត្តសញ្ញាណបឋមរបស់ជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។

១៦- អ្នកសម្ភាសន៍កុមារត្រូវមានលក្ខណៈសម្បត្តិ និងមានវិជ្ជាជីវៈច្បាស់លាស់ប្រកបដោយសីលធម៌ ដើម្បីកាត់បន្ថយការធ្វើឱ្យមានការប៉ះទង្គិចផ្លូវចិត្តឡើងវិញដល់ជនរងគ្រោះ។ រាល់ការសម្ភាសបែបកោសលវិច័យទាំងអស់ នឹងត្រូវធ្វើឡើងនៅក្នុងមជ្ឈមណ្ឌលតស៊ូមតិកុមារនៃអង្គការ A21 Foundation ដោយអនុលោមតាមគោលការណ៍ណែនាំរបស់មជ្ឈមណ្ឌលតស៊ូមតិសម្រាប់កុមារ និងបទដ្ឋានអប្បបរមាស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ។

១៧- មជ្ឈមណ្ឌលតស៊ូមតិសម្រាប់កុមារ នឹងផ្តល់នូវការគាំទ្រលើសេវាព្យាបាល ការពិនិត្យសុខភាព និងការតស៊ូមតិដើម្បីជួយដល់ជនរងគ្រោះ និងសេវាចាំបាច់ផ្សេងទៀត ដោយអនុលោមតាមក្របខ័ណ្ឌនៃធនធានដែលខ្លួនមាន។

១៨- មជ្ឈមណ្ឌលតស៊ូមតិសម្រាប់កុមារ នឹងធ្វើការសហការជាមួយដៃគូពាក់ព័ន្ធនានា ដើម្បីជួយគាំទ្រដល់ដំណើរការនៅក្នុងនីតិវិធីតុលាការ ដោយស្វែងរកដៃគូសហការផ្តល់សេវាជំនួយផ្លូវច្បាប់ជូនដល់ជនរងគ្រោះដែលបានស្នើសុំជំនួយ។

១៩- ផ្តល់ព័ត៌មាន និងរបាយការណ៍អំពីសកម្មភាព និងលទ្ធផលដែលបានអនុវត្តប្រចាំត្រីមាសតាមកាលកំណត់ មកគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្តគោលដៅ និងអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដើម្បីដាក់បញ្ចូលក្នុងរបាយការណ៍កិច្ចសហការ។

## ប្រការ ៤
## ការដោះស្រាយវិវាទ

រាល់វិវាទដែលអាចកើតឡើងពាក់ព័ន្ធនឹងការបកស្រាយ ឬការអនុវត្តអនុស្សរណៈយោគយល់នេះ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអង្គការ A21 Foundation ត្រូវដោះស្រាយតាមរយៈការចរចាដោយសន្តិវិធីរវាងភាគីទាំងពីរ ។

## ប្រការ ៥
## អវសានប្បញ្ញត្តិ

អនុស្សរណៈយោគយល់នេះ ចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខា និងមានសុពលភាព រយៈពេល ៣(បី)ឆ្នាំ ហើយអាចបន្តសុពលភាពបានទៀតដោយមានការយល់ព្រមពីភាគីទាំងពីរ។

ភាគីម្ខាងអាចជូនដំណឹងទៅភាគីម្ខាងទៀតជាលាយលក្ខណ៍អក្សរ ក្នុងពេលណាក៏បានប្រសិនបើខ្លួនមានបំណងបញ្ចប់អនុស្សរណៈយោគយល់នេះ។ ក្នុងករណីនេះ អនុស្សរណៈយោគយល់ នឹងត្រូវបញ្ចប់ក្នុងរយៈពេល ៦០(ហុកសិប)ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃការទទួលបានការជូនដំណឹង។

អនុស្សរណៈយោគយល់នេះ ធ្វើឡើងជាពីរច្បាប់ដើម ជាភាសាខ្មែរ និងភាសាអង់គ្លេស ដែលអត្ថបទទាំងពីរភាសាមានតម្លៃស្មើគ្នា។ ក្នុងករណីមិនមានការឯកភាពគ្នាលើការបកស្រាយអត្ថបទទាំងនេះ អត្ថបទជាភាសាខ្មែរត្រូវយកជាគោល ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី...២១...ខែ...វិច្ឆិកា...ឆ្នាំ២០២០

**គណៈកម្មាធិការជាតិ**
**ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស**
**អនុប្រធានអចិន្ត្រៃយ៍**

**លោកជំទាវ ជូ ប៊ុនអេង**

**អង្គការ** A21 Foundation
**នាយិកាប្រចាំប្រទេស**

**កញ្ញា គ្រីស្ទីន ស្កាហ្វ**

# ឧបសម្ព័ន្ធ

## សង្ខេបអំពីគម្រោង

- ឈ្មោះស្ថាប័ន ៖ អង្គការ A21 Foundation
- ប្រភេទស្ថាប័ន ៖ អង្គការមិនមែនរដ្ឋាភិបាលបរទេស
- បានចុះបញ្ជីនៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២០។
- អាសយដ្ឋានរបស់ស្ថាប័នអនុវត្តគម្រោង៖ ផ្ទះលេខ ១៨៦ ផ្លូវ បេតិកភណ្ឌ ភូមិស្លក្រាម សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប
- ទូរស័ព្ទ ៖ (+៨៥៥) ៦៣ ២១០ ៧៧១ / ១២ ៤២៧ ៥០២
- អ៊ីម៉ែល ៖ kristen.s@a21.org
- ឈ្មោះគម្រោង ៖ មជ្ឈមណ្ឌលតស៊ូមតិសម្រាប់កុមារ (Child Advocacy Center)
- ថវិកាអនុវត្តគម្រោង ៖ ៦៦៨,០១៦ ដុល្លារអាមេរិក
- កាលបរិច្ឆេទចាប់ផ្តើម ៖ ០៣ វិច្ឆិកា ២០២០
- កាលបរិច្ឆេទបញ្ចប់ ៖ ថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២៣
- ទីកន្លែងអនុវត្តគម្រោង ៖ ខេត្តសៀមរាប បាត់ដំបង និងបន្ទាយមានជ័យ
- ចំនួនបុគ្គលិកបរទេស ៖ ០១ នាក់
- ចំនួនបុគ្គលិកខ្មែរ ៖ ០៤ នាក់ ។